ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ.០០១៩ សុខ.នគក

ថ្ងៃពុធ ១៣កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល
## ជម្រាបជូន
## ឯកឧត្តម លោកជំទាវ លោក លោកស្រី
## ប្រធានអង្គភាពផ្តល់សេវាសុខាភិបាលសាធារណៈថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**កម្មវត្ថុ៖** ការយកចិត្តទុកដាក់អនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្តល់សេវាពិនិត្យថែទាំព្យាបាលជំងឺដល់អតីតនាយទាហានថ្នាក់ឧត្តមសេនីយ៍ និងឧត្តមនាវី នៅពេលមានជំងឺ។

**យោង៖**
- ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- អនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកំណត់អត្រាវិភាគទាន បែបបទ និងនីតិវិធីនៃការបង់វិភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុវជន
- អនុក្រឹត្យលេខ១៤១ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៣០ ជំពូកទី៣ នៃអនុក្រឹត្យលេខ១៩៩ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្តីពីបែបបទ នៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំង៥ នៃយោធិនអាជីព និងបទប្បញ្ញត្តិ ដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបថា ដើម្បីលើកកម្ពស់ការយកទឹកចិត្តទុកដាក់ក្នុងការអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តជាធរមាន សំដៅធានាបាននូវសិទ្ធិ និងផលប្រយោជន៍របស់យោធិនអាជីព អតីតយោធិនអាជីព អតីតនាយទាហានថ្នាក់ឧត្តមសេនីយ៍ និងឧត្តមនាវី នៅពេលមានជំងឺ ក្រសួងសុខាភិបាល សូមឱ្យគ្រប់អង្គភាពផ្តល់សេវាសុខាភិបាលសាធារណៈទាំងអស់ ពង្រឹងការអនុវត្តឱ្យបានកាន់តែល្អប្រសើរ តាមខ្លឹមសារនៃ មាត្រា ៣០.-ថ្មី នៃអនុក្រឹត្យ ១៤១ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ និងមាត្រា ២៣.- នៃព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលមានដូចខាងក្រោម៖

- មាត្រា៣០ថ្មី នៃអនុក្រឹត្យលេខ១៤១ អនក្រ.បក «ពេលមានជំងឺ អតីតនាយទាហានថ្នាក់ឧត្តមសេនីយ៍ និងឧត្តមនាវី ត្រូវទទួលបានការព្យាបាលនៅតាមបណ្តាញសុខាភិបាលសាធារណៈ ឬយោធា ដោយថ្លៃសេវានៃការពិនិត្យព្យាបាលជាបន្ទុករបស់រដ្ឋ។ ពេលទទួលមរណភាព ក្រសួងការពារជាតិទទួលបន្ទុករៀបចំពិធីបុណ្យសពតាមពិធីការយោធា»។ ក្នុងន័យនេះ អង្គភាពផ្តល់សេវាសុខាភិបាលសាធារណៈទាំងអស់ត្រូវយកចិត្តទុកដាក់ពិនិត្យ ថែទាំព្យាបាលជំងឺ ប្រកបដោយស្មារតីទទួលខុសត្រូវក្នុងមនសិការវិជ្ជាជីវៈ

ខ្ពស់ជូនដល់អតីតនាយទាហានថ្នាក់ឧត្តមសេនីយ៍និងឧត្តមនាវី នៅពេលមានជំងឺ ដោយថ្លៃសេវានៃការពិនិត្យព្យាបាលជាបន្ទុករបស់រដ្ឋ ដែលស្ថិតក្រោមការចំណាយរបស់អង្គភាពសុខាភិបាលសាធារណៈផ្ទាល់។

- មាត្រា២៣ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ « យោធិន អតីតយោធិនអាជីពនិងគ្រួសារផ្ទាល់របស់ពួកគេ មានសិទ្ធិព្យាបាលជំងឺនៅក្នុងមន្ទីរពេទ្យនៃកងយោធពលខេមរភូមិន្ទ»។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោក លោកស្រី** ចូលរួមអនុវត្តតាមខ្លឹមសារអនុក្រឹត្យ និងច្បាប់ខាងលើនេះដែលមានជូនភ្ជាប់មកជាមួយ ប្រកបដោយស្មារតីទទួលខុសត្រូវឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោក លោកស្រី ប្រធានអង្គភាពផ្តល់សេវាសាធារណៈសុខាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាល

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការប្រចាំការ

វេជ្ជ. ម៉ី សំបូរ

**ចម្លងជូន៖**

- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- សមាគមអតីតយុទ្ធជនកម្ពុជា
- រដ្ឋបាលរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ